# ការណែនាំអំពីរបៀបបោះឆ្នោតតាមសន្លឹកឆ្នោតក្រដាស

## របៀបគូសសន្លឹកឆ្នោតរបស់អ្នក:



- **គូសបំពេញ នៅលើ រង្វង់ រាងពងក្រពើ** នៅខាងស្ដាំនៃជម្រើសរបស់អ្នក **អោយបានពេញទាំងស្រុង**
- នៅពេលបោះឆ្នោតនៅមណ្ឌលបោះឆ្នោត សូមប្រើសញ្ញាសម្គាល់ដែលបានផ្តល់ឱ្យនៅ**មណ្ឌលបោះឆ្នោត** ដើម្បីគូសសម្គាល់សន្លឹកឆ្នោតរបស់អ្នក
- នៅពេលបោះឆ្នោតពីផ្ទះ: ប្រើប៊ិចពណ៌ខ្មៅ ឬ ពណ៌ខៀវ។ សូមកុំប្រើ ប៊ិចពណ៌ក្រហម
- សូមកុំប្រើសញ្ញាធីក X's ឆូតដូច បន្ទាត់ ឬ រង្វង់ឡើយ
- មិនត្រូវអោយមានព័ត៌មានផ្ទាល់ខ្លួន ឬ សញ្ញាសម្គាល់បង្ហាញ នៅលើ សន្លឹកឆ្នោត ផ្លូវការ របស់អ្នកឡើយ




## ការបោះឆ្នោត សរសេរ-ឈ្មោះបញ្ចូល:

- សរសេរ-បញ្ចូលឈ្មោះ បេក្ខជនដែលមានលក្ខណ:សម្បត្តិគ្រប់គ្រាន់នៅក្នុងចន្លោះទំនេរដែលបានផ្តល់ជូន
- បំពេញនៅលើរង្វង់ រាងពងក្រពើ នៅខាងស្ដាំ ទាំងស្រុង នៃចន្លោះ សរសេរ-បញ្ចូលឈ្មោះ
- សូមកុំសរសេរ- បញ្ចូលឈ្មោះបេក្ខជនដែលបានបោះពុម្ពឈ្មោះ នៅលើសន្លឹកឆ្នោត រួចហើយ

***ជៀសវាង ការបោះឆ្នោត-លើស-កំណត់។*** *ដើម្បីធានាថា អោយសន្លឹកឆ្នោតរបស់អ្នកនឹងត្រូវបានរាប់បញ្ចូល មិនត្រូវបោះឆ្នោតអោយ ច្រើនជាងចំនួនកំណត់ សម្រាប់ការប្រកួតប្រជែងនីមួយៗឡើយ។*




ប្រសិនបើអ្នកធ្វើ **ខុស** សូមស្នើសុំសន្លឹកឆ្នោតថ្មី ឬ ប្រសិនបើមិនមានពេលគ្រប់គ្រាន់ដើម្បីទទួលបានសន្លឹកឆ្នោតថ្មីតាមសំបុត្រនោះ អ្នកអាចកែវាបាន ដោយគ្រាន់តែគូសឆូតចោលនៅលើជម្រើសដែលមិនត្រឹមត្រូវនោះ ហើយ គូសបំពេញ នៅលើរង្វង់រាងពងក្រពើអោយបានត្រឹមត្រូវដូចដែលបានបង្ហាញនៅក្នុងរូបភាពនេះ។

## បោះឆ្នោតនៅមណ្ឌលបោះឆ្នោត:



- ម៉ាស៊ីនបោះឆ្នោតដែលអាចចូលប្រើបាន
- ឧបករណ៍គូសសន្លឹកឆ្នោត
- សន្លឹកឆ្នោតជំនួស/ប្រអប់ទម្លាក់សន្លឹកឆ្នោត
- សម្ភារ:បោះឆ្នោត និងជំនួយភាសា
- ការចុះឈ្មោះបោះឆ្នោត

## ការបោះឆ្នោតតាមសំបុត្រ:



- សម្រាប់ការស្នើសុំសន្លឹកឆ្នោតជំនួសថ្មី សូមហៅទៅកាន់ទូរស័ព្ទលេខ (408) 299-VOTE (8683) ឬ ហៅទៅកាន់លេខទូរស័ព្ទ ដោយឥតគិតថ្លៃ (866) 430-VOTE (8683)
- បន្ទាប់ពីគូសបំពេញនៅលើសន្លឹកឆ្នោតរបស់អ្នករួចរាល់ហើយ ដាក់សន្លឹកឆ្នោតដែលអ្នកបានបោះរួចរាល់របស់អ្នកចូលទៅក្នុងស្រោមសំបុត្រផ្ញើ ត្រឡប់មកវិញ និង**ចុះហត្ថលេខា** ឈ្មោះរបស់អ្នកបន្ទាប់ពីអក្សរក្រហម “X” ដើម្បីផ្តល់សន្លឹកឆ្នោតត្រូវបានរាប់បញ្ចូល

សន្លឹកឆ្នោតដែលបានបោះរួចរាល់របស់អ្នក ត្រូវតែ បញ្ជូនត្រឡប់មកវិញនៅ ត្រឹមម៉ោង 8 យប់ នៅក្នុង ថ្ងៃ បោះឆ្នោត ឬ ត្រូវបានវាយត្រាទទួលស្គាល់នៅថ្ងៃបោះឆ្នោត ឬ នៅ មុនពេល ថ្ងៃ បោះឆ្នោត ហើយនិងត្រូវតែអោយបានទទួលមិនអោយ យឺតជាង 7 ថ្ងៃ បន្ទាប់ ពីថ្ងៃ បោះឆ្នោត។ បញ្ជូន ឬ ផ្ញើសន្លឹកឆ្នោតរបស់អ្នក អោយបានមុនពេល ដើម្បីអាចត្រូវអោយបានរាប់បញ្ចូលនៅក្នុងលទ្ធផលនៃការបោះឆ្នោតនៅពេលយប់ដំបូង!

## ជម្រើសនៃការផ្ញើបញ្ជូនសន្លឹកឆ្នោតត្រឡប់មកវិញ:

- ✓ ផ្ញើសន្លឹកឆ្នោតរបស់អ្នកតាមសំបុត្រ។ **មិនបាច់បិទតែមទេ**
- ✓ យកទៅដាក់ **នៅតាម ប្រអប់ ទម្លាក់ សន្លឹកឆ្នោត ផ្លូវការ**
- ✓ ប្រគល់ទៅឱ្យ **មណ្ឌលបោះឆ្នោត**
- ✓ អ្នកអាចផ្តល់សិទ្ធិជាលាយលក្ខណ៍អក្សរដល់អ្នកផ្សេងក្រៅពីអ្នកបោះឆ្នោតដើម្បីបញ្ជូនសន្លឹកឆ្នោតត្រឡប់មកវិញ